- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០៩/១២០១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំង និងផ្តល់ឋានៈឯកឧត្តម **ខឹម សំអាត** ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ មានឋានៈស្មើអគ្គនាយក នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា២**:សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៩*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១១៩/០៧៤

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១**: តែងតាំង និងផ្តល់ឋានៈជាទីប្រឹក្សាក្រសួងពាណិជ្ជកម្ម ចំនួន ០២រូប ៖

១- ឯកឧត្តម **ហាន គៀក** មានឋានៈស្មើ រដ្ឋលេខាធិការ មិនទទួលយកប្រាក់បំណាច់មុខងារ

២- ឯកឧត្តម **ហុង ឈី** មានឋានៈស្មើ រដ្ឋលេខាធិការ មិនទទួលយកប្រាក់បំណាច់មុខងារ

**មាត្រា ២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

៣៧. ១៩០១.០៧៦

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៩*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១១៩/០៧៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១**: តែងតាំង និងផ្តល់ឋានៈជាទីប្រឹក្សាក្រសួងព័ត៌មាន ៖

១- ឯកឧត្តម យឿន នវ៉ា មានឋានៈស្មើ អនុរដ្ឋលេខាធិការ
២- ឯកឧត្តម សុក សុពុទ្ធី មានឋានៈស្មើ អនុរដ្ឋលេខាធិការ
៣- លោកជំទាវ ភួង ជីតា មានឋានៈស្មើ អនុរដ្ឋលេខាធិការ។

**មាត្រា ២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

៣៧.១៩០១.០៧៧

នរោត្តមសីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៩*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១១៩/០៧៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១** : តែងតាំងឯកឧត្តម **ម៉ៅ វិទ្ធីថា** ជាអនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៩*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រី ប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១១៩/០២៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម **ឃាំង ភារណុល** ជាអនុរដ្ឋលេខាធិការ ក្រសួងផែនការ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

៣៦៧.១៩០១.០២៧

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៩*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១១៩/០៧៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១** : តែងតាំងជា **អនុរដ្ឋលេខាធិការ** ក្រសួងព័ត៌មាន ចំនួន ២ រូប :

១-ឯកឧត្តម **ឃួន ទិចិត្រ**

២- ឯកឧត្តម **ឈាន ឈាង** ។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

៣៧.១៩០១.០៩០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៩*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១១៩/០៧៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៥៧ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង និងផ្តល់ឋានៈ ដល់ឯកឧត្តម ឧត្តមសេនីយ៍ទោ **សុខ ម៉ូរីត្យា** អត្តលេខ០២៤១០ ជាទីប្រឹក្សាអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានឋានៈស្មើ អគ្គនាយក។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរស.១៩០១.០៤១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៩*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៣ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការទទួលស្គាល់ការប្តូរឈ្មោះ សាកលវិទ្យាល័យហ្សាម៉ាន់ ទៅជា សាកលវិទ្យាល័យអន្តរជាតិផារ៉ាហ្គន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជននិងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ៤៧ អនក្រ.បក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០ ស្តីពីការទទួលស្គាល់សាកលវិទ្យាល័យហ្សាម៉ាន់
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១.**

ត្រូវបានទទួលស្គាល់ការប្ដូរឈ្មោះ **សាកលវិទ្យាល័យហ្សាម៉ាន់** "Zaman University" ទៅជា **សាកលវិទ្យាល័យអន្តរជាតិផារ៉ាហ្គន** "Paragon International University" សរសេរអក្សរកាត់ជាភាសាខ្មែរ " **ស.ផារ៉ាហ្គន** " និងជាភាសាអង់គ្លេស " Paragon.U "។

**មាត្រា២..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាធិការនៃសាកលវិទ្យាល័យអន្តរជាតិផារ៉ាហ្គន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៨ រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្តូរឈ្មោះវិទ្យាស្ថានអភិវឌ្ឍន៍សហគ្រិនភាពកម្ពុជា-ឥណ្ឌា ទៅជា វិទ្យាស្ថានជាតិសហគ្រិនភាព និងនវានុវត្តន៍ មានឋានៈស្មើថ្នាក់អគ្គនាយកដ្ឋាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ២៨៣អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខខណ្ឌវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២៦០ អនក្រ.បក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការប្រែក្លាយមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនកម្ពុជា-ឥណ្ឌា ទៅជាវិទ្យាស្ថានអភិវឌ្ឍន៍សហគ្រិនភាពកម្ពុជា-ឥណ្ឌា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សម្រេច

**មាត្រា១.-**

ត្រូវបានប្តូរឈ្មោះវិទ្យាស្ថានអភិវឌ្ឍន៍សហគ្រិនភាពកម្ពុជា-ឥណ្ឌា ទៅជា **"វិទ្យាស្ថានជាតិសហគ្រិនភាព និងនវានុវត្តន៍"** សរសេរជាអក្សរកាត់ថា "វ.ជ.ស.ន." និងជាភាសាអង់គ្លេសថា "National Institute of Entrepreneurship and Innovation" សរសេរជាអក្សរកាត់ថា "N.I.E.I." មានឋានៈស្មើថ្នាក់អគ្គនាយកដ្ឋាន។

**មាត្រា២.-**

វ.ជ.ស.ន. មានទីតាំងស្ថិតនៅភូមិចុងថ្នល់ខាងលិច សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៣.-**

វ.ជ.ស.ន. ធ្វើការបណ្តុះបណ្តាលដោយអនុលោមតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិលើកម្រិតជំនាញ ដូចខាងក្រោម៖

- បណ្តុះបណ្តាលផ្នែកសហគ្រិនគ្រប់កម្រិត រួមមាន វគ្គខ្លី បឋម មធ្យម ឧត្តម និងក្រោយឧត្តម
- បណ្តុះបណ្តាលគ្រូផ្នែកសហគ្រិនសម្រាប់គ្រឹះស្ថានសាធារណៈ និងឯកជន
- បណ្តុះបណ្តាលកម្រិតវិញ្ញាបនបត្រ បណ្តុះបណ្តាលវិជ្ជាជីវៈ សិក្សារយៈពេលខ្លីក្រោម១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- បណ្តុះបណ្តាលកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ សិក្សារយៈពេល១ឆ្នាំ មាន៣០ក្រេឌីត ឡើងទៅ
- បណ្តុះបណ្តាលកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ២ សិក្សារយៈពេល១ឆ្នាំ មាន៣០ក្រេឌីត ឡើងទៅ
- បណ្តុះបណ្តាលកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ៣ សិក្សារយៈពេល១ឆ្នាំ មាន៣០ក្រេឌីត ឡើងទៅ
- បណ្តុះបណ្តាលកម្រិតសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស សិក្សារយៈពេលយ៉ាងតិច២ឆ្នាំ មាន៦០ក្រេឌីត ឡើងទៅ
- បណ្តុះបណ្តាលកម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស/សញ្ញាបត្រវិស្វករ សិក្សារយៈពេលយ៉ាងតិច៤ឆ្នាំ មាន១២០ក្រេឌីត ឡើងទៅ
- បណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស សិក្សារយៈពេល២ឆ្នាំ មាន៤៥ក្រេឌីត ឡើងទៅ
- បណ្តុះបណ្តាលបណ្ឌិតបច្ចេកវិទ្យា/ឯកទេស សិក្សារយៈពេល៣ឆ្នាំ មាន៥៤ក្រេឌីតឡើងទៅ។

**មាត្រា៤.-**

វ.ជ.ស.ន. មានផ្នែក និងមហាវិទ្យាល័យ ដូចខាងក្រោម៖

១- ផ្នែករដ្ឋបាល បុគ្គលិក ផែនការ និងហិរញ្ញវត្ថុ

២- ផ្នែកអប់រំបណ្តុះបណ្តាល និងធានាគុណភាព

៣- ផ្នែកទំនាក់ទំនងឧស្សាហកម្ម និងសហប្រតិបត្តិការអន្តរជាតិ

៤- មហាវិទ្យាល័យសហគ្រិនភាព និងនវានុវត្តន៍

៥- មហាវិទ្យាល័យបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍

៦- មហាវិទ្យាល័យបច្ចេកទេស និងវិស្វកម្ម

៧- មហាវិទ្យាល័យភាសាបរទេស

៨- មហាវិទ្យាល័យធុរកិច្ច

**មាត្រា៥.-**

វ.ជ.ស.ន. មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីជួយពិនិត្យ ផ្តល់យោបល់ និងតម្រង់ទិសលើការងារបណ្តុះបណ្តាលស្របតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីសិក្សារបស់ វ.ជ.ស.ន.។

សមាសភាព និងភារកិច្ចរបស់ក្រុមប្រឹក្សាភិបាលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៦.-**

វ.ជ.ស.ន. ត្រូវដឹកនាំដោយនាយកចំនួន១ (មួយ) រូប ដែលតែងតាំងដោយព្រះរាជក្រឹត្យ (មានឋានៈស្មើអគ្គនាយក)។

វ.ជ.ស.ន. មាននាយករងចំនួន៣ (បី) រូប ដែលតែងតាំងដោយអនុក្រឹត្យ (មានឋានៈស្មើអគ្គនាយករង) និងអាចតែងតាំងមួយចំនួនទៀតតាមការចំបាច់។

វ.ជ.ស.ន. មានផ្នែក និងមហាវិទ្យាល័យនីមួយៗត្រូវដឹកនាំដោយប្រធានផ្នែក ឬព្រឹទ្ធបុរសមួយរូប ដែលតែងតាំងដោយអនុក្រឹត្យ (មានឋានៈស្មើប្រធាននាយកដ្ឋាន) និងអាចបង្កើតផ្នែក ឬមហាវិទ្យាល័យមួយចំនួនទៀតតាមការចំបាច់ ដោយរៀបចំសុំការអនុញ្ញាតពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

វ.ជ.ស.ន. មានអនុប្រធានផ្នែក និងព្រឹទ្ធបុរសរងមួយចំនួនតាមការចាំបាច់ ដែលតែងតាំងដោយប្រកាស (មានឋានៈស្មើអនុប្រធាននាយកដ្ឋាន)។

**មាត្រា៧.-**

វ.ជ.ស.ន. អាចមានទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិ និងអន្តរជាតិមួយចំនួន សម្រាប់ជួយបំពេញការងារ។

**មាត្រា៨.-**

វ.ជ.ស.ន. មានដេប៉ាតឺម៉ង់ និងការិយាល័យមួយចំនួនតាមការចាំបាច់។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ដេប៉ាតឺម៉ង់ និងការិយាល័យចំណុះ វ.ជ.ស.ន. ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៩.-**

ការចំណាយសម្រាប់ដំណើរការរបស់ វ.ជ.ស.ន. ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិ ក្នុងគម្រោងថវិការបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

វ.ជ.ស.ន. មានសិទ្ធិទទួល ចាត់ចែង និងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាន នូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀត សម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា១០.-**

វ.ជ.ស.ន. មានភារកិច្ចដូចខាងក្រោម៖

- ស្រាវជ្រាវ និងរៀបចំកម្មវិធីសិក្សាសម្រាប់សហគ្រិនភាព និងនវានុវត្តន៍
- បណ្តុះបណ្តាលសហគ្រិនភាពគ្រប់កម្រិតរួមមានវគ្គខ្លី មធ្យម ឧត្តម និងក្រោយឧត្តម
- បណ្តុះបណ្តាលគ្រូផ្នែកសហគ្រិនភាពទាំងសាធារណៈ និងឯកជន
- ផ្តល់សេវាប្រឹក្សាយោបល់ក្នុងការធ្វើជំនួញ
- ផ្តល់លិខិតបញ្ជាក់ជំនាញសហគ្រិនភាពសម្រាប់គ្រូផ្នែកសហគ្រិន និងអ្នកប្រកបអាជីវកម្មខ្នាតតូច និងមធ្យម
- បង្កើតមូលនិធិសហគ្រិនភាព ដើម្បីជំរុញ និងលើកទឹកចិត្តដល់សហគ្រិនដែលមានសក្តានុពល និងការច្នៃប្រឌិត

- ផ្តល់ចំណេះដឹង ចំណេះធ្វើ និងបច្ចេកទេសដល់សហគ្រិនថ្មី ក្នុងការបង្កើតសហគ្រាសថ្មី
- ទំនាក់ទំនងជាមួយវិទ្យាស្ថានក្នុង និងក្រៅប្រទេស អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ ក្រសួង ស្ថាប័ន និងក្រុមហ៊ុននានា ដើម្បីធ្វើការបណ្តុះបណ្តាលផ្នែកសហគ្រិន ឱ្យកាន់តែមានគុណភាព និង ប្រសិទ្ធភាព សមស្របទៅនឹងការរីកចម្រើនរបស់ទីផ្សារក្នុង និងក្រៅប្រទេស
- រៀបចំ និងបង្កើតពានរង្វាន់សហគ្រិនថ្នាក់ជាតិ
- រៀបចំជំនួបពិភាក្សា សម្រាប់សហគ្រិនជោគជ័យលើគ្រប់វិស័យ
- បង្កើតវេទិកាអ្នកដឹកនាំអាជីវកម្ម សម្រាប់ការប្រកួតប្រជែងថ្នាក់ជាតិ និងអន្តរជាតិ
- បណ្តុះបណ្តាលគ្រប់កម្រិត ដោយអនុលោមតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិ
- ផ្តល់ការបណ្តុះបណ្តាលផ្នែកពាណិជ្ជកម្មអេឡិចត្រូនិច
- ផ្តល់ការសិក្សាពីចម្ងាយគ្រប់ជំនាញ និងគ្រប់កម្រិត
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា១១.-**

សិក្ខាកាម សិស្ស និស្សិត ដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ ត្រូវទទួលបានវិញ្ញាបនបត្រ ឬសញ្ញាបត្រ តាមកម្រិត និងឯកទេសដែលបានសិក្សា។ វិញ្ញាបនបត្រ ឬសញ្ញាបត្រនេះ ត្រូវផ្តល់ឱ្យដោយ វ.ជ.ស.ន. ដែលមាន ការទទួលស្គាល់ពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថាននេះបានបំពេញ និងអនុវត្តតាម គោលការណ៍របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា១២.-**

អនុក្រឹត្យលេខ២៦០អនុក្រ.បក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការប្រែក្លាយមជ្ឈមណ្ឌលអភិវឌ្ឍន៍ សហគ្រិនកម្ពុជា-ឥណ្ឌា ទៅជាវិទ្យាស្ថានអភិវឌ្ឍន៍សហគ្រិនភាពកម្ពុជា-ឥណ្ឌា និងបទប្បញ្ញត្តិទាំងឡាយណាដែល ផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិង បណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងនាយកវិទ្យាស្ថានជាតិសហគ្រិនភាព និងនវានុវត្តន៍ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៩ កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានីភ្នំពេញ
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបន្ទាយមានជ័យ ទៅជា វិទ្យាស្ថានពហុបច្ចេកទេសខេត្តបន្ទាយមានជ័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខខណ្ឌវិនិច្ឆ័យនៃការ បង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា១ .-**

ត្រូវបានប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបន្ទាយមានជ័យ ទៅជា "**វិទ្យាស្ថានពហុបច្ចេកទេសខេត្តបន្ទាយមានជ័យ**" សរសេរជាអក្សរកាត់ថា "**វ.ព.ប.ជ.**" និងជាភាសាអង់គ្លេសថា "**Polytechnic Institute of Banteay Meanchey Province**" សរសេរជាអក្សរកាត់ថា "**P.I.B.M.C.**"។

**មាត្រា២ .-**

វ.ព.ប.ជ. មានទីតាំងស្ថិតនៅភូមិគាប សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ និងស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៣ .-**

វ.ព.ប.ជ. ធ្វើការបណ្តុះបណ្តាលដោយអនុលោមតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិលើកម្រិតជំនាញដូចខាងក្រោម៖

- កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ សិក្សារយៈពេលខ្លីក្រោម១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ ២ និង៣ សិក្សារយៈពេល១ឆ្នាំ ២ឆ្នាំ និង៣ឆ្នាំ ដែលមានយ៉ាងតិច៣០ក្រេឌីត (សម្រាប់មួយកម្រិត)
- កម្រិតសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស សិក្សារយៈពេលយ៉ាងតិច២ឆ្នាំ ដែលមានយ៉ាងតិច៦០ក្រេឌីត
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស សញ្ញាបត្រវិស្វករ សិក្សារយៈពេលយ៉ាងតិច៤ឆ្នាំ ដែលមានយ៉ាងតិច១២០ក្រេឌីត។

យន្តការ នីតិវិធី និងកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៤ .-**

វ.ព.ប.ជ. មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីជួយពិនិត្យ ផ្តល់យោបល់ និងតម្រង់ទិសលើការងារបណ្តុះបណ្តាលស្របតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីសិក្សារបស់ វ.ព.ប.ជ. ។

សមាសភាព និងភារកិច្ចរបស់ក្រុមប្រឹក្សាភិបាលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៥ .-**

វ.ព.ប.ជ. ត្រូវដឹកនាំដោយនាយក១(មួយ)រូប តែងតាំងដោយអនុក្រឹត្យ និងនាយករងមួយចំនួនតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

វ.ព.ប.ជ. មានដេប៉ាតឺម៉ង់ និងការិយាល័យមួយចំនួនតាមការចាំបាច់។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ដេប៉ាតឺម៉ង់ និងការិយាល័យចំណុះ វ.ព.ប.ជ. ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៦ .-**

វ.ព.ប.ជ. អាចមានទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិ និងអន្តរជាតិមួយចំនួន សម្រាប់ជួយបំពេញការងារ។

**មាត្រា៧ .-**

វ.ព.ប.ជ. មានសិទ្ធិប្រើត្រាដោយឡែកសម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា៨ .-**

ការចំណាយសម្រាប់ដំណើរការរបស់ វ.ព.ប.ជ. ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិ ក្នុងគម្រោងថវិការបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

វ.ព.ប.ជ. មានសិទ្ធិទទួល ចាត់ចែង និងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាន នូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀត សម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា៩ .-**

មន្ត្រីរាជការដែលបាន និងកំពុងបំពេញការងារនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបន្ទាយមានជ័យ ត្រូវផ្ទេរទៅបម្រើការងារនៅ វ.ព.ប.ជ. ដោយរក្សាទុកតួនាទីនៅដដែលរហូតដល់មានការតែងតាំងសារជាថ្មី ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា១០ .-**

វ.ព.ប.ជ. មានតួនាទីជាសេនាធិការឱ្យក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានភារកិច្ច ដូចខាងក្រោម៖

- អភិវឌ្ឍកម្មវិធីអប់រំ និងបណ្តុះបណ្តាលស្របតាមស្តង់ដាសមត្ថភាព កម្រិតគុណវុឌ្ឍិជាតិ និងតម្រូវការទីផ្សារការងារ
- កសាង និងអនុវត្តផែនការអភិវឌ្ឍរបស់វិទ្យាស្ថានរយៈពេលខ្លី មធ្យម និងវែង
- សិក្សា ស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សាជាតិ និងអន្តរជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានា
- លើកកម្ពស់សមត្ថភាពជំនាញបច្ចេកទេស និងប្រឹក្សាយោបល់ដល់មន្ត្រី និងគ្រូបច្ចេកទេស
- លើកគម្រោងថវិកាប្រចាំឆ្នាំសម្រាប់កិច្ចដំណើរការរបស់វិទ្យាស្ថាន
- គ្រប់គ្រងបុគ្គលិក គ្រូបង្រៀន គ្រូបច្ចេកទេស កម្មករ សិក្ខាកាម សិស្ស និស្សិត និងទ្រព្យសម្បត្តិរបស់វិទ្យាស្ថាន
- កៀរគរធនធានពីប្រភពផ្សេងៗទៀតសម្រាប់ការបណ្តុះបណ្តាល និងការសិក្សាស្រាវជ្រាវ
- ជ្រើសរើសសិក្ខាកាម សិស្ស និស្សិតឱ្យចូលរៀនតាមការកំណត់របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា១១ .-**

សិក្ខាកាម សិស្ស និស្សិតដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ ត្រូវទទួលបានវិញ្ញាបនបត្រ ឬសញ្ញាបត្រតាមកម្រិត និងឯកទេសដែលបានសិក្សា។ វិញ្ញាបនបត្រ ឬសញ្ញាបត្រនេះត្រូវផ្តល់ឱ្យដោយ វ.ព.ប.ជ. ដែលមានការទទួលស្គាល់ពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថាននេះបានបំពេញនិងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា១២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងនាយកវិទ្យាស្ថានពហុបច្ចេកទេសខេត្តបន្ទាយមានយជ័យ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៦ រោច ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែមករា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តបន្ទាយមានជ័យ
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ធំ ទៅជា វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ធំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខខណ្ឌវិនិច្ឆ័យនៃការ បង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា១ .-**

ត្រូវបានប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ធំ ទៅជា **"វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ធំ"** សរសេរជាអក្សរកាត់ថា **"វ.ព.ក.ធ."** ជាភាសាអង់គ្លេសថា Polytechnic Institute of Kampong Thom Province សរសេរជាអក្សរកាត់ថា "P.I.K.T."។

**មាត្រា២ .-**

វ.ព.ក.ធ. មានទីតាំងស្ថិតនៅភូមិអាចារ្យលាក់ សង្កាត់អាចារ្យលាក់ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ និងស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៣ .-**

វ.ព.ក.ធ. ធ្វើការបណ្តុះបណ្តាលដោយអនុលោមតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិ លើកម្រិតជំនាញ ដូចខាងក្រោម៖

- កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ សិក្សារយៈពេលខ្លីក្រោម១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ ២ និង៣ សិក្សារយៈពេល១ឆ្នាំ ២ឆ្នាំ និង៣ឆ្នាំ ដែលមានយ៉ាងតិច៣០ក្រេឌីត (សម្រាប់មួយកម្រិត)
- កម្រិតសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស សិក្សារយៈពេលយ៉ាងតិច២ឆ្នាំ ដែលមានយ៉ាងតិច៦០ក្រេឌីត
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស សញ្ញាបត្រវិស្វករ សិក្សារយៈពេលយ៉ាងតិច៤ឆ្នាំ ដែលមានយ៉ាងតិច១២០ក្រេឌីត។

យន្តការ នីតិវិធី និងកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៤ .-**

វ.ព.ក.ធ. មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីជួយពិនិត្យ ផ្តល់យោបល់ និងតម្រង់ទិសលើការងារបណ្តុះបណ្តាលស្របតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីសិក្សារបស់ វ.ព.ក.ធ.។

សមាសភាព និងភារកិច្ចរបស់ក្រុមប្រឹក្សាភិបាលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៥ .-**

វ.ព.ក.ធ. ត្រូវដឹកនាំដោយនាយក១(មួយ)រូប តែងតាំងដោយអនុក្រឹត្យ និងនាយករងមួយចំនួនតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

វ.ព.ក.ធ. មានដេប៉ាតឺម៉ង់ និងការិយាល័យមួយចំនួនតាមការចាំបាច់។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ដេប៉ាតឺម៉ង់ និងការិយាល័យចំណុះ វ.ព.ក.ធ. ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៦ .-**

វ.ព.ក.ធ. អាចមានទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិ និងអន្តរជាតិមួយចំនួន សម្រាប់ជួយបំពេញការងារ។

**មាត្រា៧ .-**

វ.ព.ក.ធ. មានសិទ្ធិប្រើត្រាដោយឡែកសម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា៨ .-**

ការចំណាយសម្រាប់ដំណើរការរបស់ វ.ព.ក.ធ. ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិ ក្នុងគម្រោងថវិការបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

វ.ព.ក.ធ. មានសិទ្ធិទទួល ចាត់ចែង និងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាន នូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀត សម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា៩ .-**

មន្ត្រីរាជការដែលបាន និងកំពុងបំពេញការងារនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ធំ ត្រូវផ្ទេរទៅបម្រើការងារនៅ វ.ព.ក.ធ. ដោយរក្សាទុកតួនាទីនៅដដែលរហូតដល់មានការតែងតាំងសារជាថ្មី ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា១០ .-**

វ.ព.ក.ធ. មានតួនាទីជាសេនាធិការឱ្យក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានភារកិច្ច ដូចខាងក្រោម៖

- អភិវឌ្ឍកម្មវិធីអប់រំ និងបណ្តុះបណ្តាលស្របតាមស្តង់ដាសមត្ថភាព កម្រិតគុណវុឌ្ឍិជាតិ និងតម្រូវការទីផ្សារការងារ
- កសាង និងអនុវត្តផែនការអភិវឌ្ឍរបស់វិទ្យាស្ថានរយៈពេលខ្លី មធ្យម និងវែង
- សិក្សា ស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សាជាតិ និងអន្តរជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានា
- លើកកម្ពស់សមត្ថភាពជំនាញបច្ចេកទេស និងប្រឹក្សាយោបល់ដល់មន្ត្រី និងគ្រូបច្ចេកទេស
- លើកគម្រោងថវិកាប្រចាំឆ្នាំសម្រាប់កិច្ចដំណើរការរបស់វិទ្យាស្ថាន
- គ្រប់គ្រងបុគ្គលិក គ្រូបង្រៀន គ្រូបច្ចេកទេស កម្មករ សិក្ខាកាម សិស្ស និស្សិត និងទ្រព្យសម្បត្តិរបស់វិទ្យាស្ថាន
- កៀរគរធនធានពីប្រភពផ្សេងៗទៀត សម្រាប់ការបណ្តុះបណ្តាល និងការសិក្សាស្រាវជ្រាវ
- ជ្រើសរើសសិក្ខាកាម សិស្ស និស្សិតឱ្យចូលរៀនតាមការកំណត់របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា១១ .-**

សិក្ខាកាម សិស្ស និស្សិតដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ ត្រូវទទួលបានវិញ្ញាបនបត្រ ឬសញ្ញាបត្រតាមកម្រិត និងឯកទេសដែលបានសិក្សា។ វិញ្ញាបនបត្រ ឬសញ្ញាបត្រនេះត្រូវផ្តល់ឱ្យដោយ វ.ព.ក.ធ. ដែលមានការទទួលស្គាល់ពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថាននេះបានបំពេញនិងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា១២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងនាយកវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ធំ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៨ រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តកំពង់ធំ
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤២.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរក្របខ័ណ្ឌ នាយទាហាន
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ផ្ទេរក្របខ័ណ្ឌ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូនវរសេនីយ៍ឯក **ខឿ ដារ៉ា** អត្តលេខ ០១៩៩៧៧ ជំនួយការ ឯកឧត្តម ហង្ស បូណា អគ្គនាយករង អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស ក្រសួងការពារជាតិ បច្ចុប្បន្នទៅបម្រើការងារក្នុងក្របខ័ណ្ឌ ក្រសួងមហាផ្ទៃ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ពុធ ១១កើត ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៣....អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
# រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសអោយ អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់ គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើ របស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១**..បំពាក់មេដាយ **មុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន៣៤រូប ដែលមានស្នាព្រះហស្ត និងស្នាដៃល្អ ក្នុងការអភិវឌ្ឍវិស័យព្រះពុទ្ធសាសនា ដោយបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានា នៅវត្តច័ន្ទបុរីវង្ស សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ដូចមានរាយព្រះនាម និងនាមខាងក្រោម ៖

**ក**-មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ**

| | | |
|---|---|---|
| ១-អ្នកស្រី | ឡុង | មុនីចិន្តា |
| ២-លោកបណ្ឌិត | លី | សុព័ណ៌មុនី |
| ៣-អ្នកស្រី | អុល | ណារ៉ាន់ |
| ៤-អ្នកស្រី | ហាក់ | ណៃ |

**ខ**-មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា**

| | | |
|---|---|---|
| ១-ព្រះសីហមុនី | រុន | សុខជឹម |
| ២-ព្រះតេជគុណ | ម៉ន | ម៉ៃរិទ្ធមុន្នី |
| ៣-ព្រះសាសនវរោ | ស | វ៉ា |
| ៤-លោក | ឈុន | មករា |
| ៥-លោក | អ៊ឹង | ម៉េងឡាយ |
| ៦-អ្នកស្រី | វ៉ាន់ | ស៊ីវ |
| ៧-លោក | ហ៊ុន | បូរិទ្ធ |
| ៨-លោក | ឱម | ម៉ាក់ធារី |
| ៩-អ្នកស្រី | អ៊ុំ | ដាលីន |
| ១០-អ្នកស្រី | សៀង | សុខណៃ |

| | | |
|---|---|---|
| ១១-លោក | មាស | សៃហាក់ |
| ១២-លោក | មាន | សុលី |
| ១៣-លោក | ជន់ | វណ្ណី |
| ១៤-លោក | ជន | សុវណ្ណា |
| ១៥-អ្នកស្រី | ហង្ស | ចន្ថា |
| ១៦-លោក | ហេង | គីមហៀង |
| ១៧-អ្នកស្រី | ហេង | ម្លប់ |
| ១៨-លោក | ម៉ៃ | លីមហាវ |
| ១៩-លោក | សាំង | សំអាង |
| ២០-លោក | សៀង | ម៉េងហុង |
| ២១-អ្នកស្រី | សៀង | ចាន់ហួយ |
| ២២-អ្នកស្រី | វង់ | យ៉ឹង |
| ២៣-អ្នកស្រី | ម៉ៅ | ស្រីអូន |

គ-មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ**

| | | |
|---|---|---|
| ១-លោក | រស់ | រាសី |
| ២-លោក | ឈុន | វីរៈ |
| ៣-លោក | ជុន | វណ្ណត |
| ៤-លោក | សាក់ | កញ្ចណា |
| ៥-លោក | ខន | សុខឃុន |
| ៦-Mr. | NOZAKI | SHINYA |
| ៧-អ្នកស្រី | ហាក់ | ថាវី |

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ សុក្រ ១៣ កើត ខែ បុស្ស ឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៤ អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនាឆ្នាំ ២០១៨ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ៥ ខែ តុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១.**-បំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ៤ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាង សមិទ្ធផលនានា នៅវត្តថ្មកែវ ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១ | ឧបាសិកា | សរ | សារី | នៅរាជធានីភ្នំពេញ ថវិកាចំនួន ១៣ ០០០ ដុល្លារអាមេរិក |
| ២ | ឧបាសិកា | តិច | ហៀក | នៅរាជធានីភ្នំពេញ ថវិកាចំនួន ១៣ ០០០ ដុល្លារអាមេរិក |
| ៣ | លោក | សុខ | យាង | នៅខេត្តកំពង់ឆ្នាំង ថវិកាចំនួន ១០ ០០០ ដុល្លារអាមេរិក |
| ៤ | លោក | ង៉ូវ | យាង | នៅខេត្តបន្ទាយមានជ័យ ថវិកាចំនួន ១០ ០០០ ដុល្លារអាមេរិក |

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៣ កើត ខែ បុស្ស ឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៤៥ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**សម្រេច**

**មាត្រា១**..បំពាក់មេដាយ **សំរឹទ្ធស្ថាបនាជាតិ** ប្រគេននិងជូនសប្បុរសជន ចំនួន២១រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានា នៅវត្តច័ន្ទបុរីវង្ស សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

| | | |
|---|---|---|
| ១-លោក | ឯក | សំអាត |
| ២-អ្នកស្រី | ចាប | សាវី |
| ៣-លោក | ចយ | រាជ |
| ៤-អ្នកស្រី | ឆាយ | ពេជ្ជរី |
| ៥-លោក | ងួន | ចាច់ថេត |
| ៦-លោក | វេន | សំបូរ |
| ៧-អ្នកស្រី | ភន | ស្រីម៉ុម |
| ៨-លោក | ប៊ុន | សាឯម |
| ៩-ព្រះចៅអធិការ | អ៊ែត | សំអឿន |
| ១០-លោកតា | ចាន់ | ស៊ុយ |
| ១១-លោកតា | ទឹម | ម៉ន |
| ១២-លោកតា | ញ៉ៅ | ទូច |
| ១៣-លោកតា | រស់ | វ៉ាត |

| | | |
|---|---|---|
| ១៤-លោកតា | អ៊ុន | លីវ |
| ១៥-លោកតា | ង៉ែត | វេត |
| ១៦-លោកតា | វ៉ាន់ | |
| ១៧-ឧបាសិកា | ងួន | គឹមលី |
| ១៨-ឧបាសិកា | ញ៉ៅ | ភាព |
| ១៩-ឧបាសិកា | មុំ | ហាន |
| ២០-កញ្ញា | នូ | សុវណ្ណរ័ត្ន |
| ២១-លោក | ឌិក | សារិទ្ធ |

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ សុក្រ ១៣ កើត ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៦ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរ និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ ៖** ផ្ទេរ និងតែងតាំងមុខតំណែងនាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ចំនួន ០៤ រូប នៃបណ្ឌិត្យសភានគរបាលកម្ពុជា ដូចមានរាយនាមខាងក្រោម ៖

១- លោកឧត្តមសេនីយ៍ទោ **ប្រាក់ ភូណា** អត្តលេខ ៥៥១៥៩ គ្រូនគរបាលជាតិកម្រិតឧត្តមថ្នាក់លេខ២ ជាគ្រូនគរបាលជាតិកម្រិតឧត្តមថ្នាក់លេខ១ មានឋានៈស្មើ **អគ្គនាយករង** ។

២- លោកឧត្តមសេនីយ៍ទោ **សេន សត្យា** អត្តលេខ ០៥៨៥៤ ពីគ្រូនគរបាលជាតិកម្រិតឧត្តមថ្នាក់លេខ១ ជានាយកវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រនគរបាល ។

១. អភិបាលនៃគណៈអភិបាលរាជធានីត្រូវចេញសេចក្តីសម្រេចធ្វើប្រតិភូកម្មចំណូល ចំណាយថវិកា និងអាណាប័កផ្ទេរសិទ្ធិទៅឱ្យអភិបាលនៃគណៈអភិបាលខណ្ឌ និងចៅសង្កាត់នីមួយៗ ចំណុះរាជធានី ដើម្បីអនុវត្តថវិកាដោយខ្លួនឯង ហើយផ្ញើជូនទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១ច្បាប់ និងរតនាគាររាជធានី



៧

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92. Sangkat Wat Phnom . Khan Daun Penh. Phnom Penh. CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ :៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

០១ច្បាប់ (ច្បាប់ដើម) ដោយផ្អែកលើសៀវភៅគម្រោងចំណូល ចំណាយថវិកាឆ្នាំ២០១៩ ដែលរដ្ឋបាលខណ្ឌ និងសង្កាត់នីមួយៗ បានរៀបចំរួច និងបានដាក់បញ្ចូលទៅក្នុងសៀវភៅគម្រោងចំណូល ចំណាយថវិកាឆ្នាំ២០១៩ របស់រដ្ឋបាលរាជធានីដែលត្រូវបានត្រួតពិនិត្យនីត្យានុកូលភាព និងបញ្ជាក់អនុលោមភាពទទួលស្គាល់ដោយអភិបាលនៃគណៈអភិបាលរាជធានី។

២. អភិបាលនៃគណៈអភិបាលក្រុង ត្រូវចេញសេចក្ដីសម្រេចធ្វើប្រតិភូកម្មចំណូល ចំណាយថវិកា និងអាណាប័កផ្ទេរសិទ្ធិទៅឱ្យចៅសង្កាត់នីមួយៗ ចំណុះក្រុងនីមួយៗ ដើម្បីអនុវត្តថវិកាដោយខ្លួនឯង ហើយផ្ញើជូនទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១ច្បាប់ និងរតនាគារខេត្ត ០១ច្បាប់ (ច្បាប់ដើម) ដោយផ្អែកលើសៀវភៅគម្រោងចំណូល ចំណាយថវិកាឆ្នាំ២០១៩ ដែលរដ្ឋបាលសង្កាត់នីមួយៗបានរៀបចំរួច និងបានដាក់បញ្ចូលទៅក្នុងសៀវភៅគម្រោងចំណូល ចំណាយថវិកាឆ្នាំ២០១៩ របស់រដ្ឋបាលក្រុងដែលត្រូវបានត្រួតពិនិត្យនីត្យានុកូលភាព និងបញ្ជាក់អនុលោមភាពទទួលស្គាល់ដោយអភិបាលនៃគណៈអភិបាលខេត្ត។

៣. អភិបាលនៃគណៈអភិបាលរាជធានី និងអភិបាលនៃគណៈអភិបាលក្រុង ត្រូវទទួលខុសត្រូវចំពោះថវិកាធ្វើប្រតិភូកម្មដែលអនុវត្តដោយអាណាប័កផ្ទេរសិទ្ធិ។

## ខ.អំពីចំណូល

### ខ.១.ចំណូលសារពើពន្ធ

ប្រភេទចំណូលសារពើពន្ធ ដែលច្បាប់បានអនុញ្ញាតឱ្យប្រមូលសម្រាប់ជាគុណប្រយោជន៍នៃថវិការាជធានី ខេត្ត រួមមាន អាករសម្រាប់បំភ្លឺសាធារណៈ អាករលើការស្នាក់នៅ ពន្ធប៉ាតង់ ពន្ធប្រថាប់ត្រា ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានយន្តគ្រប់ប្រភេទ ពន្ធលើអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងពន្ធលើឈ្នួលចលនទ្រព្យ និងអចលនទ្រព្យ។

រដ្ឋបាលរាជធានី ខេត្ត ត្រូវជំរុញ និងតាមដានការអនុវត្តគោលនយោបាយ និងនីតិវិធីប្រមូលចំណូលរបស់មន្ត្រីពន្ធដារ ឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិជាធរមាន និងត្រូវរួមចំណែកដាក់ចេញនូវវិធានការជាក់ស្ដែងសម្រាប់ប្រភេទពន្ធដារនីមួយៗ ដើម្បីតម្រូវឱ្យអ្នកជាប់ពន្ធបង់ពន្ធបានត្រឹមត្រូវ គ្រប់គ្រាន់ និងទាន់ពេលវេលា។ ទន្ទឹមនឹងនោះ រដ្ឋបាលរាជធានី ខេត្ត ត្រូវចាត់ឱ្យមន្ត្រីទទួលបន្ទុកប្រមូលទិន្នន័យស្ថិតិ និងកម្រងព័ត៌មានដែលជាមូលដ្ឋានក្នុងការប្រមូលពន្ធដារ សម្រាប់ជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលរាជធានី ខេត្ត ដើម្បីជាមូលដ្ឋានតាមដានត្រួតពិនិត្យ និងជួយដល់មន្ត្រីពន្ធដារក្នុងការប្រមូលចំណូល និងធ្វើជាឯកសារយោងក្នុងការរៀបចំគម្រោងចំណូលពន្ធដារសម្រាប់ឆ្នាំនីមួយៗ។

### ខ.២.ចំណូលមិនមែនសារពើពន្ធ

ចំពោះមុខសញ្ញាចំណូលមិនមែនសារពើពន្ធ ដែលច្បាប់បានអនុញ្ញាតឱ្យប្រមូលសម្រាប់ថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

ត្រូវយកចិត្តទុកដាក់ស្រាវជ្រាវ កំណត់មុខសញ្ញាចំណូល ដែលត្រូវប្រមូលបង់ចូលរតនាគារឱ្យអស់ មិនត្រូវទុកចំណូលខ្លះនៅដោយឡែកសម្រាប់ចំណាយដោយឡែកក្រៅពីគម្រោងចំណាយប្រចាំឆ្នាំឡើយ។

**១.** ចំពោះចំណូលមិនមែនសារពើពន្ធ ដែលត្រូវប្រមូលពីកម្រៃសេវាសាធារណៈរដ្ឋបាល ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមដីកាកំណត់តម្លៃសេវារដ្ឋបាលជាក់ស្តែង សម្រាប់ប្រតិបត្តិនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយផ្អែកតាមស្ថានភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានស្របតាមប្រកាសអន្តរក្រសួង លេខ ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រកាសអន្តរក្រសួងលេខ ១៤៣៤៣ ប្រក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់ថវិការង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**២.** ចំពោះចំណូលមិនមែនសារពើពន្ធផ្សេងៗទៀតដូចជា÷

- ចំណូលបានពីកម្រៃសេវាកម្មត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វនៅសត្តឃាតដ្ឋាន ត្រូវអនុវត្តតាមខ្លឹមសារអនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ ក្នុងជំពូក៥ មាត្រាទី១៦ និងប្រកាសអន្តរក្រសួងលេខ ១៣៤ សហវ.ប្រក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១។
- ចំណូលសួយសារប៉េ និងប្រាក់រង្វាន់លើកទឹកចិត្តពីប្រាក់កាត់ទុក នៃប្រាក់ចំណូលសួយសារប៉េ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសអន្តរក្រសួងលេខ ២៨៤ សហវ.ប្រក ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីអត្រាសួយសារលើតម្លៃធនធានប៉េ និងនីតិវិធីនៃការបង់ថ្លៃសួយសារ។

ចំពោះមុខសញ្ញាចំណូលដែលបានកំណត់រួចហើយ ស្ថិតក្នុងលក្ខណៈដែលត្រូវប្រមូលតាមវិធីដេញថ្លៃជាសាធារណៈនោះ ត្រូវធ្វើឱ្យមានតម្លាភាពពិតប្រាកដ មិនត្រូវបង្កើតការដេញថ្លៃតែរូបភាពនោះទេ។ ទន្ទឹមនោះ ត្រូវយកចិត្តទុកដាក់ជំរុញការបង់ចំណូលឱ្យបានត្រឹមត្រូវតាមការកំណត់ ដែលមានចែងក្នុងកិច្ចសន្យា។

**ខ.៣. ចំណូលឧបត្ថម្ភពីថវិកាជាតិ**

ចំពោះរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ដែលត្រូវបំពេញតុល្យភាពដោយការឧបត្ថម្ភពីថវិកាជាតិ ទោះបីរដ្ឋបាលនេះ បានកត់ត្រាតួលេខចំណូលឧបត្ថម្ភពីថវិកាជាតិនៅក្នុងគម្រោងថវិការបស់ខ្លួនក៏ដោយ ក៏មិនមានន័យថា ថវិកាជាតិដាច់ខាតត្រូវតែឧបត្ថម្ភតាមចំនួននោះទេ។ ចំណូលឧបត្ថម្ភពីថវិកាជាតិ គឺត្រូវពិនិត្យជូនរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ដោយផ្អែកទៅតាមស្ថានភាពជាក់ស្តែងនៃតុល្យភាពថវិកាជាតិ និងទៅតាមសភាពការណ៍ជាក់ស្តែងនៃការអនុវត្តចំណូល ចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក។

**២.៣.១ ចំណូលឧបត្ថម្ភពីថវិកាជាតិប្រចាំត្រីមាស**

ចំពោះចំណូលនេះ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវធ្វើសំណើសុំឧបត្ថម្ភតុល្យភាពពីថវិកាជាតិប្រចាំត្រីមាសនីមួយៗដូចតទៅ ÷

**១.** ចំពោះរដ្ឋបាលរាជធានី ខេត្ត ត្រូវធ្វើសំណើសុំឧបត្ថម្ភតុល្យភាពពីថវិកាជាតិប្រចាំត្រីមាសនីមួយៗមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈក្រសួងមហាផ្ទៃ។

**២.** ចំពោះរដ្ឋបាលក្រុង ស្រុក ត្រូវធ្វើសំណើសុំឧបត្ថម្ភតុល្យភាពពីថវិកាជាតិប្រចាំត្រីមាសនីមួយៗមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមរយៈរដ្ឋបាលខេត្ត ។

នៅដើមត្រីមាសទី១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងផ្តល់ថវិកាឧបត្ថម្ភជូនរដ្ឋបាលខេត្ត ក្រុង ស្រុក ដោយមិនបាច់មានការស្នើសុំទេ។ ដោយឡែកសម្រាប់ត្រីមាសទី២ ទី៣ និងទី៤ រដ្ឋបាលខេត្ត ក្រុង ស្រុក ត្រូវធ្វើសំណើសុំថវិកាឧបត្ថម្ភតុល្យភាពពីថវិកាជាតិនៅសប្តាហ៍ទី១ ដើមខែនៃចុងត្រីមាសមុន សំណើសុំនេះត្រូវមកដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ដើមខែនៃត្រីមាសនីមួយៗដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

- របាយការណ៍អនុវត្តចំណូលជាក់ស្តែង ដែលមានហត្ថលេខាបញ្ជាក់របស់រតនាគារ រាជធានី ខេត្ត
- របាយការណ៍ប៉ាន់ស្មានចំណូលសម្រាប់ត្រីមាសបន្ទាប់ ដោយមានបែងចែកតាមខែនីមួយៗ ដោយភ្ជាប់នូវរបាយការណ៍ប៉ាន់ស្មានរបស់សាខាពន្ធដារខេត្ត និងឯកសារគាំទ្រ
- របាយការណ៍អនុវត្តចំណាយជាក់ស្តែង ដែលមានហត្ថលេខាបញ្ជាក់របស់អាណាប័ក
- លិខិតសន្យាចំណាយថវិកា សលាកប័ត្រគត់ត្រាចំណាយ និងត្រួតពិនិត្យហិរញ្ញវត្ថុ (ដូចមានគំរូជូនភ្ជាប់ជាមួយ) អាណត្តិបើកប្រាក់ (ថតចម្លង) ដែលអាណាប័កបានចុះហត្ថលេខារួច
- របាយការណ៍ប៉ាន់ស្មានចំណាយសម្រាប់ត្រីមាសបន្ទាប់ ដោយភ្ជាប់មកនូវឯកសារសម្រាប់គាំទ្រ (ឯកសារលទ្ធកម្មសាធារណៈដែលពាក់ព័ន្ធដល់ការទូទាត់) ដូចមានគំរូតារាងឧបសម្ព័ន្ធ "ក១" - "ក២" និងតារាងឧបសម្ព័ន្ធ "ខ១" - "ខ២" ជូនភ្ជាប់ជាមួយ។

**៣.** ចំពោះកញ្ចប់សេវាអនាម័យបរិស្ថាននៅដើមត្រីមាសទី១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងផ្តល់ថវិកាសេវាអនាម័យបរិស្ថានដោយមិនបាច់មានការស្នើសុំឡើយ។ ដោយឡែក សម្រាប់ត្រីមាសទី២ ទី៣ និងទី៤ រដ្ឋបាលក្រុងគោលដៅនីមួយៗត្រូវធ្វើសំណើសុំឧបត្ថម្ភកញ្ចប់ថវិកាសេវាអនាម័យបរិស្ថានមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈមន្ទីរបរិស្ថានខេត្តដោយមានភ្ជាប់ឯកសារលិខិតយុត្តិការដូចខាងក្រោម÷

- របាយការណ៍អនុវត្តចំណូល ចំណាយប្រចាំខែអំពីសេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ និងលទ្ធផលការងារដែលសម្រេចបាន
- របាយការណ៍ប៉ាន់ស្មានចំណូល ចំណាយប្រចាំត្រីមាសបន្ទាប់ ដោយមានការបែងចែកតាមខែនីមួយៗ សម្រាប់ការ អនុវត្តសេវាអនាម័យបរិស្ថានរួមទាំងឯកសារគាំទ្រ ដូចជាសេចក្តីចម្លងកិច្ចសន្យារវាង

រដ្ឋបាលក្រុង និងដៃគូផ្តល់សេវាអនាម័យបរិស្ថាន ផែនការសកម្មភាពការងារសេវាអនាម័យបរិស្ថាន គ្រប់គ្រងសំណល់រឹង រាវ។

រតនាគាររាជធានី ខេត្ត ដែលជាគណនេយ្យករសាធារណៈ និងជាគណនេយ្យករមុខការ នៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវជូនដំណឹងអំពីស្ថានភាពគណនីប្រាក់បញ្ញើនៅរៀងរាល់ដើមសប្តាហ៍នីមួយៗដល់ថ្នាក់រដ្ឋបាលទាំងអស់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ខ.៣.២ ចំណូលឧបត្ថម្ភពីថវិការាជធានី**

**ខ.៣.២.១.ចំណូលឧបត្ថម្ភពីថវិការាជធានីជូនខណ្ឌ**

រដ្ឋបាលរាជធានី ត្រូវធ្វើអាណត្តិបើកប្រាក់ផ្ទេរឥណទានថវិកាពីអនុគណនី៦៥០១២ (ឧបត្ថម្ភធនដល់ ក្រុង ស្រុក ខណ្ឌ) ជូនបណ្តារដ្ឋបាលខណ្ឌប្រចាំត្រីមាសនីមួយៗ ហើយរដ្ឋបាលខណ្ឌត្រូវធ្វើសំណើសុំឧបត្ថម្ភថវិកា ពីរដ្ឋបាលរាជធានីដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

- របាយការណ៍អនុវត្តចំណូលជាក់ស្តែងដែលមានហត្ថលេខាបញ្ជាក់របស់រតនាគាររាជធានី
- របាយការណ៍ប៉ាន់ស្មានចំណូលសម្រាប់ត្រីមាសបន្ទាប់ដោយមានបែងចែកតាមខែនីមួយៗ ដោយភ្ជាប់នូវឯកសារសម្រាប់គាំទ្រ
- របាយការណ៍អនុវត្តចំណាយជាក់ស្តែងដែលមានហត្ថលេខាបញ្ជាក់របស់អាណាប័កផ្ទេរសិទ្ធិ
- លិខិតសន្យាចំណាយថវិកា សលាកប័ត្រកត់ត្រាចំណាយ និងត្រួតពិនិត្យហិរញ្ញវត្ថុ (ដូចមានគំរូ ជូនភ្ជាប់ជាមួយ) អាណត្តិបើកប្រាក់ (ថតចម្លង) ដែលអាណាប័កបានចុះហត្ថលេខារួច
- របាយការណ៍ប៉ាន់ស្មានចំណាយសម្រាប់ត្រីមាសបន្ទាប់ ដោយភ្ជាប់តាមនូវឯកសារសម្រាប់គាំទ្រ (ឯកសារលទ្ធកម្មសាធារណៈដែលពាក់ព័ន្ធដល់ការទូទាត់)ដូចមានគំរូតារាងឧបសម្ព័ន្ធ “ក១” - “ក២” និងតារាងឧបសម្ព័ន្ធ “ខ១” - “ខ២” ជូនភ្ជាប់ជាមួយ។

**ខ.៣.២.២.ចំណូលឧបត្ថម្ភពីថវិការាជធានីជូនសង្កាត់ ÷**

រដ្ឋបាលរាជធានី ត្រូវធ្វើអាណត្តិបើកប្រាក់ផ្ទេរឥណទានថវិកាពីអនុគណនី៦៥០១៣ (ឧបត្ថម្ភធនដល់ឃុំ សង្កាត់) ជូនបណ្តារដ្ឋបាលសង្កាត់ប្រចាំត្រីមាសនីមួយៗផ្អែកលើតួលេខទទួលបានពីការវិភាជន៍មូលនិធិឃុំ សង្កាត់ ហើយរដ្ឋបាលសង្កាត់ត្រូវធ្វើសំណើសុំឧបត្ថម្ភថវិកាពីរដ្ឋបាលរាជធានីដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

- របាយការណ៍អនុវត្តចំណូលជាក់ស្តែងដែលមានហត្ថលេខាបញ្ជាក់របស់រតនាគាររាជធានី
- របាយការណ៍ប៉ាន់ស្មានចំណូលសម្រាប់ត្រីមាសបន្ទាប់ ដោយមានបែងចែកតាមខែនីមួយៗដោយភ្ជាប់នូវឯកសារសម្រាប់គាំទ្រ
- របាយការណ៍អនុវត្តចំណាយជាក់ស្តែងដែលមានហត្ថលេខាបញ្ជាក់របស់អាណាប័កផ្ទេរសិទ្ធិ
- លិខិតសន្យាចំណាយថវិកា សលាកប័ត្រកត់ត្រាចំណាយ និងត្រួតពិនិត្យហិរញ្ញវត្ថុ (ដូចមានគំរូ ជូនភ្ជាប់ជាមួយ) អាណត្តិបើកប្រាក់ (ថតចម្លង) ដែលអាណាប័កបានចុះហត្ថលេខារួច

- របាយការណ៍ប៉ាន់ស្មានចំណាយសម្រាប់ត្រីមាសបន្ទាប់ ដោយភ្ជាប់តាមនូវឯកសារសម្រាប់គាំទ្រ (ឯកសារលទ្ធកម្មសាធារណៈដែលពាក់ព័ន្ធដល់ការទូទាត់) ដូចមានគំរូតារាងឧបសម្ព័ន្ធ "ក១" - "ក២" និងតារាងឧបសម្ព័ន្ធ "ខ១" - "ខ២" ជូនភ្ជាប់ជាមួយ។

**ខ.៣.២.៣.ចំណូលឧបត្ថម្ភចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្តជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់**

- រដ្ឋបាលរាជធានី នៅពេលដែលទទួលបានសលាកប័ត្របង់ប្រាក់ និងតារាងបែងចែកលម្អិតពន្ធលើចំណូលពីសារពើពន្ធ ជូនរដ្ឋបាលខណ្ឌនីមួយៗ និងរដ្ឋបាលសង្កាត់នីមួយៗពីអគ្គនាយកដ្ឋានពន្ធដារ សាខាពន្ធដារខណ្ឌ រដ្ឋបាលរាជធានី ត្រូវធ្វើអាណត្តិបើកប្រាក់ផ្ទេរឥណទានថវិកាមួយត្រីមាសម្តង ជូនរដ្ឋបាលខណ្ឌ ពីអនុគណនី៦៥០១២ (ឧបត្ថម្ភធនដល់ក្រុង ស្រុក ខណ្ឌ) និងផ្ទេរឥណទានថវិកាជូនរដ្ឋបាលសង្កាត់ពីអនុគណនី៦៥០១៣ (ឧបត្ថម្ភធនដល់ឃុំ សង្កាត់)។
- រដ្ឋបាលខេត្ត នៅពេលដែលទទួលបានសលាកប័ត្របង់ប្រាក់ និងតារាងបែងចែកលម្អិតពន្ធលើចំណូលសារពើពន្ធ ជូនរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់នីមួយៗ ពីអគ្គនាយកដ្ឋានពន្ធដារ សាខាពន្ធដារខេត្ត រដ្ឋបាលខេត្តត្រូវធ្វើអាណត្តិបើកប្រាក់ផ្ទេរឥណទានថវិកាមួយត្រីមាសម្តងជូនរដ្ឋបាលក្រុង ស្រុក ពីអនុគណនី៦៥០១២ (ឧបត្ថម្ភធនដល់ក្រុង ស្រុក ខណ្ឌ) និងឃុំ សង្កាត់នីមួយៗពីអនុគណនី៦៥០១៣(ឧបត្ថម្ភធនដល់ ឃុំ សង្កាត់)។ នៅដើមឆ្នាំថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងចេញប្រកាសស្តីពីការបន្ថែមឥណទាន៣% នៃចំណូលសារពើពន្ធរបស់រាជធានី ខេត្ត ជូនរដ្ឋបាលក្រុង ស្រុក និងចេញសេចក្តីជូនដំណឹងស្តីពីទំហំឥណទាន១% នៃចំណូលសារពើពន្ធរបស់រាជធានី ខេត្ត ជូនរដ្ឋបាលឃុំ សង្កាត់ យោងតាមប្រកាសលេខ ១៤៥៨ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការបែងចែកចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្ត ជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

**ខ.៣.២.៤.ចំណូលឧបត្ថម្ភពីថវិកាខេត្តជូនរដ្ឋបាលក្រុង(សេវាអនាម័យបរិស្ថាន)**

រដ្ឋបាលខេត្ត នៅពេលទទួលបាននូវអាណត្តិផ្ទេរឥណទានថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការឧបត្ថម្ភថវិកាសម្រាប់សេវាអនាម័យបរិស្ថាន រដ្ឋបាលខេត្តត្រូវធ្វើអាណត្តិបើកប្រាក់ផ្ទេរឥណទានថវិកាជូនរដ្ឋបាលក្រុងនីមួយៗចំណុះខេត្តសាមី ពីអនុគណនី៦៥០១២(ឧបត្ថម្ភធនដល់ក្រុង ស្រុក ខណ្ឌ)

**ខ.៣.៣. ចំណូលឧបត្ថម្ភពីថវិការដ្ឋបាលក្រុង**

រដ្ឋបាលក្រុង ត្រូវធ្វើអាណត្តិបើកប្រាក់ផ្ទេរឥណទានថវិកាពីអនុគណនី៦៥០១៣ (ឧបត្ថម្ភធនដល់ឃុំ សង្កាត់) ជូនបណ្តារដ្ឋបាលសង្កាត់ប្រចាំត្រីមាសនីមួយៗផ្អែកលើតួលេខទទួលបានពីការវិភាជន៍មូលនិធិឃុំ សង្កាត់ ហើយសង្កាត់ត្រូវធ្វើសំណើសុំឧបត្ថម្ភពីថវិកាក្រុង ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ÷

- របាយការណ៍អនុវត្តចំណូលជាក់ស្តែងដែលមានហត្ថលេខាបញ្ជាក់របស់រតនាគារខេត្ត

- របាយការណ៍ប៉ាន់ស្មានចំណូលសម្រាប់ត្រីមាសបន្ទាប់ ដោយមានបែងចែកតាមខែនីមួយៗ ដោយភ្ជាប់នូវឯកសារសម្រាប់គាំទ្រ
- របាយការណ៍អនុវត្តចំណាយជាក់ស្តែងដែលមានហត្ថលេខាបញ្ជាក់របស់អាណាប័កផ្ទេរសិទ្ធិ
- លិខិតសន្យាចំណាយថវិកា សលាកប័ត្រកត់ត្រាចំណាយ និងត្រួតពិនិត្យហិរញ្ញវត្ថុ (ដូចមានគំរូជូនភ្ជាប់ជាមួយ) អាណត្តិបើកប្រាក់ (ថតចម្លង) ដែលអាណាប័កបានចុះហត្ថលេខារួច
- របាយការណ៍ប៉ាន់ស្មានចំណាយសម្រាប់ត្រីមាសបន្ទាប់ ដោយភ្ជាប់តាមនូវឯកសារសម្រាប់គាំទ្រ (ឯកសារលទ្ធកម្មសាធារណៈដែលពាក់ព័ន្ធដល់ការទូទាត់) ដូចមានគំរូតារាងឧបសម្ព័ន្ធ "ក១" - "ក២" និងតារាងឧបសម្ព័ន្ធ "ខ១" - "ខ២" ជូនភ្ជាប់ជាមួយ។

**ខ.៣.៤ ចំណូលឧបត្ថម្ភពីថវិកាជាតិសម្រាប់វិនិយោគសាធារណៈ**

ចំណូលនេះគ្រាន់តែជាការផ្ទេរឥណទានថវិកាជាតិ សម្រាប់អនុវត្តនូវកម្មវិធីចំណាយវិនិយោគសាធារណៈទៅក្នុងថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ដូច្នេះពេលស្នើសុំ គឺរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវធ្វើសំណើត្រង់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែម្តង។ ការស្នើនេះចែកចេញជាពីរយ៉ាង ÷

**ខ.៣.៤.១.ឧបត្ថម្ភសម្រាប់មូលនិធិបដិភាគ**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ផ្អែកលើតួលេខដែលបានគ្រោងក្នុងសៀវភៅថវិការាជធានី ខេត្ត ក្រុង ស្រុក ឬប្រកាសបន្ថែមឥណទាន ត្រូវធ្វើសំណើដោយភ្ជាប់មកជាមួយនូវគម្រោងកម្មវិធីវិនិយោគសាធារណៈនៃហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ដែលត្រូវអនុវត្តនៅរាជធានី ខេត្ត ក្រុង ស្រុក។

**ខ.៣.៤.២.ឧបត្ថម្ភវិនិយោគដោយថវិកាជាតិ**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ផ្អែកលើតួលេខដែលបានគ្រោងក្នុងសៀវភៅថវិការាជធានី ខេត្ត ក្រុង ស្រុក ឬ ប្រកាសបន្ថែមឥណទានត្រូវធ្វើសំណើដោយភ្ជាប់មកជាមួយនូវឯកសារដែលបានធ្វើលទ្ធកម្មសាធារណៈរួចតាមការដ្ឋាននីមួយៗ។

**គ.អំពីចំណាយ**

**គ.១.ចំណាយចរន្ត**

ចំណាយចរន្ត រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់ទៅតាមគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុដូចគ្នានៃចំណាយថវិកាជាតិដែរ ពោលគឺ ÷

- អំពីចំណាយបៀវត្សត្រូវជំរុញអនុវត្តការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារ និងអនុវត្តតាមអនុក្រឹត្យ ១៧៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការកែប្រែតម្លៃនៃឯកតាសន្ទស្សន៍មូលដ្ឋានរបស់មន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា។ ជាមួយគ្នានេះផងដែរ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវខិតខំសម្រេចឱ្យបាននូវការបើកបៀវត្សជូនមន្ត្រីរាជការ មន្ត្រីសាធារណៈ សមាជិកក្រុមប្រឹក្សា និងមន្ត្រីភូមិ ដោយយោងតាមសារាចរលេខ ០៧ សរ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្ស

រៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ជូនមន្ត្រីរាជការស៊ីវិលមន្ត្រីសាធារណៈផ្សេងទៀត និងត្រូវអនុលោមតាមបទប្បញ្ញត្តិជាធរមាន។ ចំពោះបៀវត្សរបស់មន្ត្រីរាជការ និងប្រាក់កម្រៃមន្ត្រីជាប់កិច្ចសន្យា ត្រូវអនុវត្តតាមរយៈភ្នាក់ងារបើកផ្តល់តាមតារាងបើកប្រាក់ ដែលចេញ និងបានផ្តល់ទិដ្ឋាការដោយក្រសួងមុខងារសាធារណៈ (ករណីដែលមន្ត្រីទាំងនោះមិនទាន់បានបើកបៀវត្សតាមប្រព័ន្ធធនាគារ) និងផ្អែកលើអនុក្រឹត្យលេខ ១៧២ អនក្រ.បក ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការដំឡើងប្រាក់កម្រៃប្រចាំខែជូនមន្ត្រីជាប់កិច្ចសន្យា, អនុក្រឹត្យលេខ ២៧៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការដំឡើងប្រាក់វិភាជន៍គ្រួសាររបស់មន្ត្រីរាជការស៊ីវិល ប្រាក់បំណាច់ឧបត្ថម្ភគ្រួសារ និងកូនយោធិន នៃកងយោធពលខេមរភូមិន្ទ មន្ត្រីនគរបាលជាតិកម្ពុជា មន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ, អនុក្រឹត្យលេខ ១៩៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការកែប្រែ និងដំឡើងប្រាក់ឧបត្ថម្ភមាតុភាពជូនមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាជាស្ត្រីដែលសម្រាលកូន និងប្រាក់ឧបត្ថម្ភបុណ្យសពជូនគ្រួសារសពមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាដែលទទួលមរណភាព។ ចំណែកប្រាក់ឧបត្ថម្ភចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមខ្លឹមសារអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ ស្តីពីការកែប្រែនិងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រហូតមានលិខិតបទដ្ឋានគតិយុត្តឱ្យមកជំនួស។

- អំពីចំណាយតូចតាច និងចំណាយចាំបាច់បន្ទាន់ គឺត្រូវអនុវត្តតាមរជ្ជទេយ្យបុរេប្រទានដែលកំណត់ឡើងដោយដីការបស់គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់។ ពេលដកប្រាក់ពីរតនាគារ រជ្ជទេយ្យករត្រូវមានប័ណ្ណដកប្រាក់ និងលិខិតឧទ្ទេសនាមរបស់អង្គភាព (ពុំចាំបាច់ធ្វើលិខិតស្នើសុំឆ្លងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ឬមន្ត្រីត្រួតពិនិត្យថវិកា)។ ចំពោះការចំណាយតាមរយៈរជ្ជទេយ្យបុរេប្រទាន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវអនុវត្តតាមខ្លឹមសារ នៃប្រកាសលេខ ១៥៨៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការកែសម្រួលប្រការ១៣ នៃប្រកាសលេខ ២៧៥ សហវ.ប្រក ចុះថ្ងៃទី១០ខែមីនា ឆ្នាំ២០១៥ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

- អំពីចំណាយចរន្តផ្សេងៗទៀត គឺត្រូវអនុវត្តតាមនីតិវិធីទូទាត់ត្រង់ជូនអ្នកផ្គត់ផ្គង់ក្រោយពេលដែលទំនិញ ឬសេវានានាត្រូវបានអនុវត្តរួចហើយ។

ដោយឡែក ការអនុវត្តចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក ត្រូវអនុវត្តតាមសារាចរលេខ ០០២ សហវ.ហម ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការអនុវត្តនីតិវិធីប្រព័ន្ធទូទាត់ និងប្រព័ន្ធគណនេយ្យរបស់រដ្ឋបាលក្រុង ស្រុក។

- អំពីឥណទាន (ចំណាយមិនបានគ្រោងទុកជំពូក៦៩) រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មិនអាចអនុវត្តចំណាយជំពូកនេះដោយផ្ទាល់បានទេ ត្រូវអនុវត្តដូចខាងក្រោម÷



ៗ៣

ចំពោះរដ្ឋបាលរាជធានី ខេត្ត នៅពេលមានតម្រូវការចំណាយជំពូកនេះអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវលើកគម្រោង និងធ្វើនិយ័តកម្មឥណទានឆ្លងការអនុម័តពីក្រុមប្រឹក្សា បន្ទាប់មកត្រូវធ្វើសំណើសុំការយល់ព្រមជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈក្រសួងមហាផ្ទៃ។

ចំពោះរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅពេលមានតម្រូវការចំណាយជំពូកនេះ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវលើកគម្រោង និងធ្វើនិយ័តកម្មឥណទានឆ្លងការអនុម័តពីក្រុមប្រឹក្សា បន្ទាប់មកត្រូវធ្វើសំណើសុំការយល់ព្រមជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈអភិបាលនៃគណៈអភិបាលរាជធានី ខេត្តសាមី។

ការបង្វែរឥណទានពីជំពូកនេះ ទៅជាប្រយោជន៍ដល់ជំពូកចំណាយដទៃទៀតតាមតម្រូវការចំណាយជាក់ស្តែងនីមួយៗជាពិសេសអាទិភាពសម្រាប់តម្រូវការលក្ខណៈប្រាក់បៀវត្ស និងការងារអភិវឌ្ឍន៍ជាគុណប្រយោជន៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

### គ.២.ចំណាយជាមូលធន

ចំពោះការចំណាយជាមូលធន គឺចែកចេញជាពីរ ៖

#### គ.២.១. ចំណាយមូលនិធិបដិភាគ

ក្នុងពេលអនុវត្ត រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើអាណត្តិដោយគ្រាន់តែភ្ជាប់នូវគម្រោងកម្មវិធីវិនិយោគសាធារណៈ នៃហិរញ្ញប្បទានពីក្រៅប្រទេសតែប៉ុណ្ណោះ។ រតនាគាររាជធានី ខេត្ត ត្រូវបើកផ្តល់ ឬផ្ទេរឥណទាននេះទៅក្នុងគណនីម្ចាស់ជំនួយនៅរតនាគាររាជធានី ខេត្ត ឬធនាគារ(បើមាន)។

#### គ.២.២.ចំណាយវិនិយោគ

ចំណាយវិនិយោគ ទោះជាហិរញ្ញប្បទានដោយថវិការាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬហិរញ្ញប្បទានដោយថវិកាជាតិឧបត្ថម្ភក៏ដោយគឺត្រូវតែអនុវត្តឱ្យបានម៉ឺងម៉ាត់ទៅតាមគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុដូចគ្នានៃចំណាយថវិកាជាតិដែរ ពោលគឺត្រូវបំពេញបែបបទ និងអនុវត្តឱ្យបានត្រឹមត្រូវទៅតាមនីតិវិធីលទ្ធកម្មសាធារណៈជាធរមាន និងធ្វើអាណត្តិទូទាត់ឱ្យបានទាន់ពេលវេលាតាមការិយបរិច្ឆេទ ដែលបានកំណត់ក្នុងសៀវភៅបន្ទុក ឬកិច្ចសន្យា។

### គ.៣.ការកែតម្រូវគម្រោងថវិកា

យោងប្រការ៤២ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងករណីការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិធ្វើឱ្យលេចចេញនូវឱនភាពរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវម្ចាស់ការដាក់ចេញនូវវិធានការគ្រប់បែបយ៉ាង ដើម្បីធានាតុល្យភាពថវិកាឡើងវិញ។

នៅក្នុងឆ្នាំថវិកា ប្រសិនបើចំណូលជាក់ស្តែងនៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិបានកើនលើសពីគម្រោងចំណូលប្រចាំឆ្នាំដែលបានគ្រោងទុក ឥណទានចំណាយថវិកាអាចត្រូវបង្កើនឡើង ឬធ្វើនិយ័តកម្មទៅជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិនានាដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច

និងហិរញ្ញវត្ថុ ទៅតាមកម្រិតចំណូលលើសដែលបានបញ្ជាក់។ នៅដំណាច់ឆ្នាំថវិកា អតិរេកថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកត់ត្រាចូលគណនីលទ្ធផលនៃរតនាគារជាតិ។ ដូច្នេះ នៅពេលអនុវត្តថវិកា រដ្ឋបាលរាជធានី ខេត្ត ត្រូវពិនិត្យការអនុវត្តចំណូលរបស់ខ្លួន ដោយមានមូលដ្ឋានជាក់លាក់ដែលអាចប្រមូលចំណូលបានយ៉ាងពិតប្រាកដ រួចប្រៀបធៀបជាមួយគម្រោងចំណូលប្រចាំឆ្នាំ។ ប្រសិនបើមានចំណូលលើសពីគម្រោងចំណូលប្រចាំឆ្នាំ រដ្ឋបាលរាជធានី ខេត្ត អាចស្នើសុំបន្ថែមលើគម្រោងចំណាយប្រចាំឆ្នាំសម្រាប់ចំណាយជាគុណប្រយោជន៍របស់រដ្ឋបាលរាជធានី ខេត្ត។ រដ្ឋបាលរាជធានី ខេត្ត ត្រូវធ្វើសំណើស្នើសុំចំណាយអភិវឌ្ឍន៍នៅចុងត្រីមាសទី៣ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវគម្រោងចំណាយលម្អិតតាមការដ្ឋាននីមួយៗហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើការពិនិត្យនិងបូកសរុបបែងចែកមួយផ្នែកជូនរដ្ឋបាលរាជធានី ខេត្ត និងមួយផ្នែកទៀតបង់ចូលថវិការដ្ឋ។

ចំពោះការប្រើប្រាស់អតិរេកនៃថវិការដ្ឋបាលរាជធានី ខេត្ត ដែលកន្លងទៅត្រូវបានបែងចែកឱ្យប្រើប្រាស់តាមច្បាប់សម្រាប់ការអភិវឌ្ឍមូលដ្ឋាន ជាពិសេសវិនិយោគហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅត្រីមាសទី៤ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងធ្វើការណែនាំតាមក្រោយ ម្យ៉ាងដើម្បីជៀសវាងហានិភ័យផ្សេងៗនិយាយជារួម ហើយម្យ៉ាងទៀត ដើម្បីអនុវត្តឱ្យបានពេញលេញនូវនីតិវិធីហិរញ្ញវត្ថុជាធរមាននិយាយដោយឡែក។

ចំពោះរដ្ឋបាលក្រុង ស្រុក នៅពេលដែលកញ្ចប់ថវិកាមានទំហំតូច និងសមត្ថភាពមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុនៅមានកម្រិត អតិរេកថវិកាត្រូវបានអនុញ្ញាតឱ្យបូកយោងទៅឆ្នាំបន្ទាប់ រដ្ឋបាលក្រុង ស្រុក ត្រូវលើកគម្រោងចំណាយអភិវឌ្ឍន៍មូលដ្ឋានដោយឆ្លងការអនុម័តពីក្រុមប្រឹក្សាក្រុង ស្រុក និងស្នើសុំការប្រកាសបន្ថែមឥណទានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ចំពោះថវិកាដែលមានប្រភពពីដៃគូអភិវឌ្ឍន៍ ដូចជា÷ UNICEF UNCDF និងថវិកាមានប្រភពពីថវិការដ្ឋតាមរយៈ ការផ្ទេរមុខងាររបស់ក្រសួងសាមីដូចជាសេវាអនាម័យបរិស្ថាន ការជួសជុលថែទាំប្រព័ន្ធទឹកស្អាតនៅជនបទដែលនៅពុំទាន់បានប្រើប្រាស់ថវិកាអស់ត្រូវលើកគម្រោងចំណាយបន្ត និងស្នើសុំប្រកាសបន្ថែមឥណទានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ចំពោះរដ្ឋបាលសង្កាត់ បើមានអតិរេកថវិកា ត្រូវលើកគម្រោងចំណាយអភិវឌ្ឍន៍មូលដ្ឋានបន្ថែមដោយឆ្លងការអនុម័តពីក្រុមប្រឹក្សា ដើម្បីបូកសរុបនៅក្នុងលទ្ធផលនៃការអនុវត្តថវិកាឆ្នាំ២០១៩ ហើយត្រូវបញ្ជូនទៅបូកបញ្ចូលក្នុងលទ្ធផលនៃការអនុវត្តថវិកាឆ្នាំ២០១៩ របស់រដ្ឋបាលរាជធានី និងរដ្ឋបាលក្រុង។

**គ.៤.ការបង្វែរឥណទាន**

ការបង្វែរ (និយ័តភាព) ឥណទានត្រូវបានអនុញ្ញាតឱ្យអនុវត្តចាប់ពីដើមត្រីមាសទី៣។ ដោយឡែករដ្ឋបាលខេត្ត ដែលអនុវត្តថវិកាកម្មវិធី ត្រូវបានអនុញ្ញាតឱ្យធ្វើនិយ័តភាពចាប់ពីត្រីមាសទី២ អនុលោមតាមប្រកាសលេខ ១៦៧ សហវ.ប្រក ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំ ស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។



ៗ ស

ក្នុងករណីមានការចាំបាច់និយ័តភាពថវិកាពីអនុគណនីមួយ ទៅអនុគណនីមួយ ពីគណនីមួយ ទៅគណនីមួយ និងពីជំពូកមួយ ទៅជំពូកមួយផ្សេងទៀតនោះ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវស្នើនិយ័តភាពដូចខាងក្រោម÷

- ចំពោះរដ្ឋបាលរាជធានី ខេត្ត និយ័តភាពថវិកាពីអនុគណនីមួយ ទៅអនុគណនីមួយ ពីគណនីមួយ ទៅគណនីមួយ និងពីជំពូកមួយ ទៅជំពូកមួយផ្សេងទៀតនោះ ត្រូវធ្វើសំណើសុំនិយ័តភាពមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈក្រសួងមហាផ្ទៃ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ចំណាយជាក់ស្តែង ដែលបានអនុវត្តកន្លងមក និងគម្រោងប៉ាន់ស្មានចំណាយលម្អិតដល់បំណាច់ឆ្នាំ ព្រមទាំងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធការស្នើសុំនិយ័តភាព។

- ចំពោះរដ្ឋបាលខណ្ឌ និយ័តភាពថវិកាពីអនុគណនីមួយ ទៅអនុគណនីមួយ ពីគណនីមួយ ទៅគណនីមួយ និងពីជំពូកមួយ ទៅជំពូកមួយផ្សេងទៀតនោះ ត្រូវធ្វើសំណើសុំនិយ័តភាពមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋបាលរាជធានី ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ចំណាយជាក់ស្តែង ដែលបានអនុវត្តកន្លងមក និងគម្រោងប៉ាន់ស្មានចំណាយលម្អិតដល់បំណាច់ឆ្នាំព្រមទាំងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធការស្នើសុំនិយ័តភាព។

- ចំពោះរដ្ឋបាលក្រុង ស្រុក និយ័តភាពថវិកាពីអនុគណនីមួយ ទៅអនុគណនីមួយទៀត ពីគណនីមួយ ទៅគណនីមួយទៀតក្នុងជំពូកតែមួយ (លើកលែងគណនី៦១០៥១ ដល់គណនី៦១០៥៧ នៃជំពូក៦១ ជំពូក២០ និងជំពូក២១ នៃចំណាយមូលធន) អភិបាលនៃគណៈអភិបាលក្រុង ស្រុក អាចស្នើសុំការអនុម័ត និងមានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ដោយមានការយល់ព្រមពីគណៈអភិបាលខេត្ត (មិនអនុញ្ញាតការធ្វើនិយ័តកម្មថវិកាពីចំណាយអភិវឌ្ឍន៍ទៅបម្រើឱ្យចំណាយរដ្ឋបាលជាច់ខាត)។ ការធ្វើនិយ័តកម្មថវិកាពីជំពូកមួយ ទៅជំពូកមួយទៀត អភិបាលនៃគណៈអភិបាលក្រុង ស្រុក ត្រូវធ្វើការស្នើសុំការអនុម័តពីក្រុមប្រឹក្សាក្រុង ស្រុក និងត្រូវធ្វើសំណើសុំការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋបាលខេត្ត ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ចំណាយជាក់ស្តែងដែលបានអនុវត្តកន្លងមក និងគម្រោងប៉ាន់ស្មានចំណាយលម្អិតដល់ដំណាច់ឆ្នាំ ព្រមទាំងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធការស្នើសុំនិយ័តភាព។

## ឃ.ការរៀបចំកម្មវិធីនិងរបាយការណ៍ចំណូល ចំណាយ

### ឃ.១.ការរៀបចំកម្មវិធីចំណូល ចំណាយ

ផ្អែកលើគម្រោងថវិកាប្រចាំឆ្នាំ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានប្រកាសស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូលនិងបែងចែកឥណទានចំណាយថវិការាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ រាជធានី ខេត្ត ត្រូវរៀបចំកម្មវិធីចំណូល ចំណាយថវិកាប្រចាំត្រីមាស និងត្រូវផ្ញើកម្មវិធីចំណូល ចំណាយនោះទៅរតនាគាររាជធានី ខេត្ត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ទ/ ហ៊

និងក្រសួងមហាផ្ទៃ យ៉ាងយូរបំផុតមួយសប្តាហ៍នៃដើមត្រីមាសនីមួយៗ ។ ដោយឡែក ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកម្មវិធីចំណូល ចំណាយថវិកាប្រចាំត្រីមាស និងត្រូវផ្ញើកម្មវិធីចំណូល ចំណាយនោះ ទៅរតនាគាររាជធានី ខេត្ត រដ្ឋបាលរាជធានី ខេត្ត និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយូរបំផុតមួយសប្តាហ៍នៃដើមត្រីមាសនីមួយៗ។ ដោយឡែកសម្រាប់ត្រីមាសទី២ ទី៣ និងទី៤ ពេលផ្ញើកម្មវិធីចំណូល ចំណាយប្រចាំត្រីមាសមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ គឺដាច់ខាតត្រូវតែភ្ជាប់មកជាមួយនូវរបាយការណ៍ស្តីពីការអនុវត្តថវិកានៃត្រីមាសមុន។ កម្មវិធីចំណូល ចំណាយប្រចាំត្រីមាស គឺជាឯកសារគោលដើម្បីវិភាគក្នុងការផ្តល់ឧបត្ថម្ភធនុល្យភាពពីថវិការដ្ឋ។

**ឃ.២.ការរៀបចំរបាយការណ៍ចំណូល ចំណាយ**

រៀងរាល់ខែ ត្រីមាស ឆមាស និងដំណាច់ឆ្នាំ ទីចាត់ការហិរញ្ញវត្ថុរបស់រដ្ឋបាលរាជធានី ខេត្ត ការិយាល័យរដ្ឋបាលហិរញ្ញវត្ថុរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិការបស់ខ្លួនជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមតារាងឧបសម្ព័ន្ធ “ក១”និងឧបសម្ព័ន្ធ “ក២” ដូចបានភ្ជាប់មកជាមួយ រួចផ្ញើមកក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយូរ១៥ថ្ងៃ ក្រោយពេលបញ្ចប់ការិយបរិច្ឆេទនីមួយៗ។

ចំពោះរដ្ឋបាលឃុំ សង្កាត់ រៀងរាល់ត្រីមាស ឆមាស និងដំណាច់ឆ្នាំ ស្មៀនឃុំ សង្កាត់ ត្រូវធ្វើរបាយការណ៍ បូកសរុបការអនុវត្តចំណូល ចំណាយថវិការបស់ខ្លួន ជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត តាមតារាងឧបសម្ព័ន្ធ “គ១” និងឧបសម្ព័ន្ធ “គ២” ដូចបានភ្ជាប់ជាមួយ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយូរ១៥ថ្ងៃ ក្រោយពេលបញ្ចប់ការិយបរិច្ឆេទនីមួយៗ។

មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូល ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ តាមតារាងឧបសម្ព័ន្ធ “ឃ១” “ឃ២” “ង១” “ង២” និង “ច១” “ច២” ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយូរ២១ថ្ងៃ ក្រោយពេលបញ្ចប់ការិយបរិច្ឆេទនីមួយៗ ស្របតាមប្រកាសលេខ ៩៥៩ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

រដ្ឋបាលឃុំ សង្កាត់ ត្រូវផ្ញើសៀវភៅចំណូល ចំណាយថវិកាឆ្នាំ២០១៩ (រៀបចំតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា) របស់ខ្លួន ដែលបានដាក់ត្រួតពិនិត្យនីត្យានុកូលភាព និងបញ្ជាក់អនុលោមភាពទទួលស្គាល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត។

**ង.ការចំណាយថវិកាតាមកម្មវិធី**

ចំពោះរដ្ឋបាលខេត្តចំនួន ១៨ ដែលត្រូវដាក់ឱ្យអនុវត្តថវិកាកម្មវិធីឆ្នាំ២០១៩ ដូចជាខេត្តប៉ៃលិន ខេត្តក្រចេះ ខេត្តកំពង់ស្ពឺ ខេត្តកោះកុង ខេត្តកែប ខេត្តស្ទឹងត្រែង ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តតាកែវ ខេត្តកំពត ខេត្តព្រៃវែង ខេត្តរតនៈគិរី ខេត្តកណ្តាល ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តស្វាយរៀង ខេត្តត្បូងឃ្មុំ និងខេត្តមណ្ឌលគិរី ត្រូវអនុវត្តតាមខ្លឹមសារប្រកាសលេខ ១៦៧ សហវ.ប្រក ចុះថ្ងៃទី១៤



ᥛᥴ

ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្ដីពីនីតិវិធីអនុវត្តថវិកាកម្មវិធី របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ខាងលើនេះ គឺជាការណែនាំបន្ថែមក្នុងកិច្ចប្រតិបត្តិការថវិការាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ឱ្យចំទិសដៅ និងមានប្រសិទ្ធភាពសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ដោយឡែកប្រកាសលេខ ២០៣ ប្រក.សហវ.ថ ស្ដីពីបទបញ្ជាថវិការបស់ខេត្ត ក្រុង និងប្រកាសលេខ ២០៥ ប្រក.សហវ.ថ ស្ដីពីកិច្ចប្រតិបត្តិការអនុវត្តថវិកាខេត្ត ក្រុង ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៩៩ ដែលមិនផ្ទុយនឹងប្រកាសនេះ នៅរក្សាសុពលភាពដដែល។៚

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**<u>ចម្លងជូន:</u>**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
- ក្រសួងមហាផ្ទៃ

  "ដើម្បីជូនជ្រាប"
- គ្រប់សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- គ្រប់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត
- គ្រប់រតនាគាររាជធានី ខេត្ត
- គ្រប់សាខាពន្ធដាររាជធានី ខេត្ត

  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានី ខេត្ត...
រដ្ឋបាលក្រុង ស្រុក ខណ្ឌ...

**ការគ្រប់គ្រងឆ្នាំ២០១៩**

**របាយការណ៍ចំណូលថវិកាប្រចាំខែ........ឆ្នាំ២០១៩**

**របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

តារាងឧបសម្ព័ន្ធ "ក១"

ឯកតា:រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៩ | បណ្តាខែមុន | អនុវត្តក្នុងខែ | សរុប | ប្រៀបធៀប |
|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4=2+3 | 5=4/1 |
| | | | | | | | | |

ថ្ងៃទី ខែ ឆ្នាំ២០១៩
**អ្នកធ្វើតារាង**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៩
**នាយកទីចាត់ការហិរញ្ញវត្ថុរាជធានី ខេត្ត**
**ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុក្រុង ស្រុក ខណ្ឌ**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៩
**ប្រធានរតនាគាររាជធានី ខេត្ត**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៩
**ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត**

បានឃើញ និងឯកភាព
ថ្ងៃទី ខែ ឆ្នាំ២០១៩
**អភិបាល**
**នៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានី ខេត្ត...
រដ្ឋបាលក្រុង ស្រុក ខណ្ឌ...

ការគ្រប់គ្រងឆ្នាំ២០១៩

របាយការណ៍ចំណាយថវិកាប្រចាំខែ........ឆ្នាំ២០១៩

របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

តារាងឧបសម្ព័ន្ធ "ក២"

ឯកតា:រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៩ | ឥណទានអនុញ្ញាត | បណ្តាខែមុន | អនុវត្តក្នុងខែ | សរុប | ប្រៀបធៀប |
|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4 | 5=3+4 | 6=5/2 |
| | | | | | | | | | |

បានឃើញ និងឯកភាព
ថ្ងៃទី ខែ ឆ្នាំ២០១៩
**អភិបាល**
**នៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៩
**ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៩
**ប្រធានរតនាគាររាជធានី ខេត្ត**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៩
**នាយកទីចាត់ការហិរញ្ញវត្ថុរាជធានី ខេត្ត**
**ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុក្រុង ស្រុក ខណ្ឌ**

ថ្ងៃទី ខែ ឆ្នាំ២០១៩
**អ្នកធ្វើតារាង**

ៗ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រដ្ឋបាលរាជធានី ខេត្ត...
រដ្ឋបាលក្រុង ស្រុក ខណ្ឌ...

## ការគ្រប់គ្រងឆ្នាំ២០១៩
## គម្រោងប៉ាន់ស្មានចំណូលថវិកាសម្រាប់ត្រីមាសទី....ឆ្នាំ២០១៩
## របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

តារាងឧបសម្ព័ន្ធ "ខ១"
ឯកតា:រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៩ | អនុវត្ត.....ខែ | ប៉ាន់ស្មានត្រីមាស... | | | | សរុប ប៉ាន់ស្មាន | ប្រៀបធៀប |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | សរុប | ខែ | ខែ | ខែ | | |
| | | | | 1 | 2 | 3=4+5+6 | 4 | 5 | 6 | 7=2+3 | 8=7/1 |
| | | | | | | | | | | | |

បានឃើញ និងឯកភាព
ថ្ងៃទី ខែ ឆ្នាំ២០១៩
**អភិបាលនៃគណៈអភិបាល**
**រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៩
**ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៩
**នាយកទីចាត់ការហិរញ្ញវត្ថុរាជធានី ខេត្ត**
**ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុក្រុង ស្រុក ខណ្ឌ**

ថ្ងៃទី ខែ ឆ្នាំ២០១៩
**អ្នកធ្វើតារាង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានី ខេត្ត...
រដ្ឋបាលក្រុង ស្រុក ខណ្ឌ...

**ការគ្រប់គ្រងឆ្នាំ២០១៩**

**គម្រោងប៉ាន់ស្មានចំណាយថវិកាសម្រាប់ត្រីមាសទី....ឆ្នាំ២០១៩**

**របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

តារាងឧបសម្ព័ន្ធ "ខ២"
ឯកតា:រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៩ | ឥណទានអនុញ្ញាត | អនុវត្ត.....ខែ | ប៉ាន់ស្មានត្រីមាស... | | | | សរុប ប៉ាន់ស្មាន | ប្រៀបធៀប |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | សរុប | ខែ | ខែ | ខែ | | |
| | | | | 1 | 2 | 3 | 4=5+6+7 | 5 | 6 | 7 | 8=3+4 | 9=8/2 |
| | | | | | | | | | | | | |

បានឃើញ និងឯកភាព
ថ្ងៃទី ខែ ឆ្នាំ២០១៩
**អភិបាលនៃគណៈអភិបាល**
**រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៩
**ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៩
**នាយកទីចាត់ការហិរញ្ញវត្ថុរាជធានី ខេត្ត**
**ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុក្រុង ស្រុក ខណ្ឌ**

ថ្ងៃទី ខែ ឆ្នាំ២០១៩
**អ្នកធ្វើតារាង**

៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត.....
ក្រុង ស្រុក ខណ្ឌ......
ឃុំ សង្កាត់...

**ការគ្រប់គ្រងឆ្នាំ២០១៩**
**របាយការណ៍ចំណូលថវិកាប្រចាំត្រីមាស.....ឆ្នាំ២០១៩**
**របស់ឃុំ សង្កាត់**

តារាងឧបសម្ព័ន្ធ "គ១"
ឯកតា:រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៩ | បណ្តាត្រីមាស | អនុវត្តត្រីមាស | សរុប | ប្រៀបធៀប |
|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4=2+3 | 5=4/1 |
| | | | | | | | | |

បានឃើញ និងឯកភាព
ថ្ងៃទី ខែ ឆ្នាំ២០១៩
**អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

បានឃើញ និងឯកភាព
ថ្ងៃទី ខែ ឆ្នាំ២០១៩
**មេឃុំ ចៅសង្កាត់**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៩
**ប្រធានរតនាគាររាជធានី ខេត្ត**

ថ្ងៃទី ខែ ឆ្នាំ២០១៩
**អ្នកធ្វើតារាង**

៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត.....
ក្រុង ស្រុក ខណ្ឌ......
ឃុំ សង្កាត់...

**ការគ្រប់គ្រងឆ្នាំ២០១៩**
**របាយការណ៍ចំណាយថវិកាប្រចាំត្រីមាស....ឆ្នាំ២០១៩**
**របស់ឃុំ សង្កាត់**

តារាងឧបសម្ព័ន្ធ "គ២"
ឯកតា:រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៩ | ឥណទានអនុញ្ញាត | បណ្ដាត្រីមាស | អនុវត្តត្រីមាស | សរុប | ប្រៀបធៀប |
|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4 | 5=3+4 | 6=5/2 |
| | | | | | | | | | |

បានឃើញ និងឯកភាព
ថ្ងៃទី ខែ ឆ្នាំ២០១៩
**អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

បានឃើញ និងឯកភាព
ថ្ងៃទី ខែ ឆ្នាំ២០១៩
**មេឃុំ ចៅសង្កាត់**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៩
**ប្រធានរតនាគាររាជធានី ខេត្ត**

ថ្ងៃទី ខែ ឆ្នាំ២០១៩
**អ្នកធ្វើតារាង**

៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត

តារាងឧបសម្ព័ន្ធ: "ឃ.១"

## តារាងបូកសរុបចំណូលថវិការាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
## សម្រាប់ការគ្រប់គ្រងប្រចាំត្រីមាសទី..... ឆ្នាំ២០១៩

ឯកតា:រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុ | | | | | | អនុវត្តជាក់ស្តែង | | | | | | សមាមាត្រប្រៀបធៀប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុបរួម | រាជធានី ខេត្ត | សរុបក្រុង | សរុប ស្រុក ខណ្ឌ | សរុបសង្កាត់ | សរុបឃុំ | សរុបរួម | រាជធានី ខេត្ត | សរុបក្រុង | សរុប ស្រុក ខណ្ឌ | សរុបសង្កាត់ | សរុបឃុំ | |
| | | | | 1=2+3+4+5+6 | 2 | 3 | 4 | 5 | 6 | 7=8+9+10+11+12 | 8 | 9 | 10 | 11 | 12 | 13=7/1 |
| | | | | | | | | | | | | | | | | |

បានឃើញ និងឯកភាព
ថ្ងៃទី ខែ ឆ្នាំ២០១៩
**អភិបាលនៃគណៈអភិបាល**
**រាជធានី ខេត្ត**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៩
**ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៩
**ប្រធានការិយាល័យហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ**

ថ្ងៃទី ខែ ឆ្នាំ២០១៩
ហត្ថលេខា
**អ្នកធ្វើតារាង**

ៗ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត

## តារាងបូកសរុបចំណាយថវិការាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
## សម្រាប់ការគ្រប់គ្រងប្រចាំត្រីមាសទី..... ឆ្នាំ២០១៩

តារាងឧបសម្ព័ន្ធៈ "ឃ.២"

ឯកតាៈរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ | | | | | | ឥណទានអនុញ្ញាត | | | | | | អនុវត្តជាក់ស្តែង | | | | | | សមាមាត្រប្រៀបធៀប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុបរួម | រាជធានី ខេត្ត | សរុបក្រុង | សរុប ស្រុក ខណ្ឌ | សរុប សង្កាត់ | សរុបឃុំ | សរុបរួម | រាជធានី ខេត្ត | សរុបក្រុង | សរុប ស្រុក ខណ្ឌ | សរុប សង្កាត់ | សរុបឃុំ | សរុបរួម | រាជធានី ខេត្ត | សរុប ក្រុង | សរុប ស្រុក ខណ្ឌ | សរុប សង្កាត់ | សរុបឃុំ | |
| | | | | 1=2+3+4+5+6 | 2 | 3 | 4 | 5 | 6 | 7=8+9+10+11+12 | 8 | 9 | 10 | 11 | 12 | 13=14+15+16+17+18 | 14 | 15 | 16 | 17 | 18 | 19=13/7 |
| | | | | | | | | | | | | | | | | | | | | | | |

ថ្ងៃទី ខែ ឆ្នាំ២០១៩

ហត្ថលេខា
**អ្នកធ្វើតារាង**

បានឃើញ និងឯកភាព
ថ្ងៃទី ខែ ឆ្នាំ២០១៩
**អភិបាលនៃគណៈអភិបាល**
**រាជធានី ខេត្ត**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៩
**ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៩
**ប្រធានការិយាល័យហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត

តារាងឧបសម្ព័ន្ធៈ "ង.១"

## តារាងបូកសរុបចំណូលថវិការាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ សម្រាប់ការគ្រប់គ្រងប្រចាំត្រីមាសទី..... ឆ្នាំ២០១៩

ឯកតាៈរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុ | | | | | | អនុវត្តជាក់ស្តែង | | | | | | សមាមាត្រប្រៀបធៀប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុបរួម | រាជធានី ខេត្ត | សរុបក្រុង | សរុប ស្រុក ខណ្ឌ | សរុបសង្កាត់ | សរុបឃុំ | សរុបរួម | រាជធានី ខេត្ត | សរុបក្រុង | សរុប ស្រុក ខណ្ឌ | សរុបសង្កាត់ | សរុបឃុំ | |
| | | | | 1=2+3+4+5+6 | 2 | 3 | 4 | 5 | 6 | 7=8+9+10+11+12 | 8 | 9 | 10 | 11 | 12 | 13=7/1 |
| | | | | | | | | | | | | | | | | |

ថ្ងៃទី ខែ ឆ្នាំ២០១៩

| | | | |
|---|---|---|---|
| បានឃើញ និងឯកភាព<br>ថ្ងៃទី ខែ ឆ្នាំ២០១៩<br>**អភិបាលនៃគណៈអភិបាល**<br>**រាជធានី ខេត្ត** | បានឃើញ និងពិនិត្យត្រឹមត្រូវ<br>ថ្ងៃទី ខែ ឆ្នាំ២០១៩<br>**ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត** | បានឃើញ និងពិនិត្យត្រឹមត្រូវ<br>ថ្ងៃទី ខែ ឆ្នាំ២០១៩<br>**ប្រធានការិយាល័យហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ** | ហត្ថលេខា<br>**អ្នកធ្វើតារាង** |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត

តារាងឧបសម្ព័ន្ធៈ"ង.២"

## តារាងបូកសរុបចំណាយថវិការាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
## សម្រាប់ការគ្រប់គ្រងប្រចាំត្រីមាសទី..... ឆ្នាំ២០១៩

ឯកតាៈរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ | | | | | | ឥណទានអនុញ្ញាត | | | | | | អនុវត្តជាក់ស្តែង | | | | | | សមាមាត្រប្រៀបធៀប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុបរួម | រាជធានី ខេត្ត | សរុបក្រុង | សរុប ស្រុក ខណ្ឌ | សរុប សង្កាត់ | សរុបឃុំ | សរុបរួម | រាជធានី ខេត្ត | សរុបក្រុង | សរុប ស្រុក ខណ្ឌ | សរុប សង្កាត់ | សរុបឃុំ | សរុបរួម | រាជធានី ខេត្ត | សរុប ក្រុង | សរុប ស្រុក ខណ្ឌ | សរុប សង្កាត់ | សរុបឃុំ | |
| | | | | 1=2+3+4+5+6 | 2 | 3 | 4 | 5 | 6 | 7=8+9+10+11+12 | 8 | 9 | 10 | 11 | 12 | 13=14+15+16+17+18 | 14 | 15 | 16 | 17 | 18 | 19=13/7 |
| | | | | | | | | | | | | | | | | | | | | | | |

ថ្ងៃទី ខែ ឆ្នាំ២០១៩

| បានឃើញ និងឯកភាព | បានឃើញ និងពិនិត្យត្រឹមត្រូវ | បានឃើញ និងពិនិត្យត្រឹមត្រូវ | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ខែ ឆ្នាំ២០១៩ | ថ្ងៃទី ខែ ឆ្នាំ២០១៩ | ថ្ងៃទី ខែ ឆ្នាំ២០១៩ | អ្នកធ្វើតារាង |
| **អភិបាលនៃគណៈអភិបាល រាជធានី ខេត្ត** | **ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត** | **ប្រធានការិយាល័យហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ** | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត

តារាងឧបសម្ព័ន្ធ "ច.១"

## តារាងបូកសរុបចំណូលថវិការាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩

ឯកតា:រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុ | | | | | | អនុវត្តជាក់ស្តែង | | | | | | សមាមាត្រ ប្រៀបធៀប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុបរួម | រាជធានី ខេត្ត | សរុបក្រុង | សរុប ស្រុក ខណ្ឌ | សរុបសង្កាត់ | សរុបឃុំ | សរុបរួម | រាជធានី ខេត្ត | សរុបក្រុង | សរុប ស្រុក ខណ្ឌ | សរុបសង្កាត់ | សរុបឃុំ | |
| | | | | 1=2+3+4+5+6 | 2 | 3 | 4 | 5 | 6 | 7=8+9+10+11+12 | 8 | 9 | 10 | 11 | 12 | 13=7/1 |
| | | | | | | | | | | | | | | | | |

ថ្ងៃទី ខែ ឆ្នាំ២០១៩

បានឃើញ និងឯកភាព
ថ្ងៃទី ខែ ឆ្នាំ២០១៩
**អភិបាលនៃគណៈអភិបាល**
**រាជធានី ខេត្ត**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៩
**ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៩
**ប្រធានការិយាល័យហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ**

ហត្ថលេខា
**អ្នកធ្វើតារាង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត

តារាងឧបសម្ព័ន្ធៈ "ច.២"

## តារាងបូកសរុបចំណាយថវិការាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩

ឯកតាៈរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ | | | | | | ឥណទានអនុញ្ញាត | | | | | | អនុវត្តជាក់ស្តែង | | | | | | សមាមាត្រ ប្រៀបធៀប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុបរួម | រាជធានី ខេត្ត | សរុបក្រុង | សរុប ស្រុក ខណ្ឌ | សរុប សង្កាត់ | សរុបឃុំ | សរុបរួម | រាជធានី ខេត្ត | សរុបក្រុង | សរុប ស្រុក ខណ្ឌ | សរុប សង្កាត់ | សរុបឃុំ | សរុបរួម | រាជធានី ខេត្ត | សរុប ក្រុង | សរុប ស្រុក ខណ្ឌ | សរុប សង្កាត់ | សរុបឃុំ | |
| | | | | 1=2+3+4+5+6 | 2 | 3 | 4 | 5 | 6 | 7=8+9+10+11+12 | 8 | 9 | 10 | 11 | 12 | 13=14+15+16+17+18 | 14 | 15 | 16 | 17 | 18 | 19=13/7 |
| | | | | | | | | | | | | | | | | | | | | | | |

ថ្ងៃទី ខែ ឆ្នាំ២០១៩

បានឃើញ និងឯកភាព
ថ្ងៃទី ខែ ឆ្នាំ២០១៩
**អភិបាលនៃគណៈអភិបាល**
**រាជធានី ខេត្ត**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៩
**ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៩
**ប្រធានការិយាល័យហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ**

ហត្ថលេខា
**អ្នកធ្វើតារាង**

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី